ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# គោលការណ៍ណែនាំ

# ស្តីពី

# គុណវុឌ្ឍិ និងលក្ខខណ្ឌសម្រាប់វិញ្ញាបនបត្រវិជ្ជាជីវៈ

គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ADB LOAN – CAM 3167

ថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០១៧

# បុព្វកថា

នយោបាយ "ឈ្នះ-ឈ្នះ" របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យប្រទេសជាតិទាំងមូលទទួលបាននូវសុខសន្តិភាព ឯកភាពជាតិ ទឹកដីដ៏ពេញលេញ និងស្ថេរភាពនយោបាយ។ ប្រការនេះគឺជាកត្តាគន្លឹះធ្វើឲ្យប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពក្នុងការធ្វើឲ្យមានប្រក្រតីភាពឡើងវិញនៃជីវិតរស់នៅជាមួយនឹងសេដ្ឋកិច្ចជាតិមានការកើនឡើងយ៉ាងឆាប់រហ័ស។

ការរីកចម្រើននេះបង្ហាញឲ្យឃើញពីជោគជ័យក្នុងដំណើរផ្លូវដ៏វែងឆ្ងាយ និងដ៏លំបាកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការអភិវឌ្ឍធនធានមនុស្ស ដែលត្រូវបានបំផ្លិចបំផ្លាញដោយវិវាទអសន្តិសុខ និងអស្ថេរភាពអស់រយៈពេលជិតបីទសវត្សរ៍មក។ ទោះបីជារាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលធំៗដ៏ច្រើនក៏នៅមានបញ្ហាប្រឈមជាច្រើនទៀត ដែលត្រូវដោះស្រាយ ដើម្បីរំដោះប្រជាពលរដ្ឋចេញពីភាពក្រីក្រ ហើយសម្រេចបាននូវសកម្មភាពរួមរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុង "យុទ្ធសាស្ត្រចតុកោណ"។ តាមរយៈផែនការយុទ្ធសាស្ត្រនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ចេញនូវផែនការសកម្មភាពអាទិភាពមួយចំនួនដូចមានចែងនៅក្នុងផែនការសកម្មភាពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨។

ការចងក្រងឯកសារគោលការណ៍ណែនាំគុណវុឌ្ឍិ និងលក្ខខណ្ឌសម្រាប់វិញ្ញាបនបត្រវិជ្ជាជីវៈដែលមានន័យស្មើនឹងគុណវុឌ្ឍិជាតិកម្រិត១ គឺសំដៅបង្កើតឲ្យមានជាឯកសារគោលដែលធានានូវប្រសិទ្ធភាព និងឯកភាពនៃការអនុវត្តកម្មវិធីអប់រំបណ្តុះបណ្តាល។ ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារអភិវឌ្ឍន៍អាស៊ីដែលបានផ្តល់ប្រាក់កម្ចីសម្រាប់គម្រោង TVET–SDP សម្រាប់ចងក្រងឯកសារនេះឡើង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អង្គភាព និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍នានានឹងប្រើប្រាស់ឯកសារនេះធ្វើជាត្រីវិស័យសម្រាប់ដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាប្រកបដោយជោគជ័យដើម្បីឈានទៅសម្រេចបាននូវការកាត់បន្ថយអត្រាគ្មានការងារធ្វើ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧

**រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងជានាយកគម្រោង**

**ពេជ្រ សោភ័ន**

# មាតិកា

ទំព័រ


១. សេចក្តីផ្តើម……………………………………………………………………………………..៤

២. ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា…………………………………………………………………..៤

៣. ការពិពណ៌នាអំពីវិញ្ញាបនបត្រវិជ្ជាជីវៈ……………………………………………………….៦

៣.១. សមត្ថភាពទូទៅ…………………………………………………………………………….៧

៣.២. ការបែងចែកលទ្ធផលសិក្សាតាមផ្នែកទាំង៥……………………………………………..៧

៣.៣. លក្ខខណ្ឌចូលរៀន……………………………………………………………………………..៨

៣.៤. រយៈពេលបណ្តុះបណ្តាល………………………………………………………………….…៨

៣.៥. ប្រភេទនៃការបណ្តុះបណ្តាល………………………………………………………………..៨

៣.៦. ប្រកសិក្សា ឬធ្វើតេស្តដើម្បីទទួលបានគុណវុឌ្ឍិ……………………………………….៩

៤. ការធានាគុណភាព…………………………………………………………………………..៩

៥. ការត្រួតពិនិត្យវាយតម្លៃ និងសវនកម្ម………………………………………………….១០

៦. សន្ទានុក្រម………………………………………………………………………………….១០

## ១. សេចក្តីផ្តើម

វិញ្ញាបនបត្រវិជ្ជាជីវៈ គឺជាកម្មវិធីបណ្តុះបណ្តាលក្នុងប្រព័ន្ធដែលនាំអោយទទួលបាននូវគុណវុឌ្ឍិដែលទទួលស្គាល់ដោយថ្នាក់ជាតិ វិញ្ញាបនបត្រវិជ្ជាជីវៈត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ឲ្យអ្នកធ្វើការកម្រិតដំបូងទទួលបានចំណេះដឹង និងជំនាញដែលទាក់ទងនឹងការងារ។ ស្តង់ដាការងារដែលគាំទ្រវិញ្ញាបនបត្រវិជ្ជាជីវៈត្រូវបានផ្ទៀងផ្ទាត់ត្រួតពិនិត្យដោយផ្នែកឧស្សាហកម្ម និងគាំទ្រដោយគណៈកម្មការបណ្តុះបណ្តាលថ្នាក់ជាតិ វិញ្ញាបនបត្រវិជ្ជាជីវៈមានតម្លៃស្មើគុណវុឌ្ឍិកម្រិត១។

គោលការណ៍ណែនាំ និងបទប្បញ្ញត្តិសម្រាប់វិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបានរៀបចំឡើងដើម្បីជូនដំណឹង និងណែនាំដល់អ្នកផ្តល់ការបណ្តុះបណ្តាលដែលបានចុះបញ្ជិកាក្នុងការចែកចាយ និងវាយតម្លៃគុណវុឌ្ឍិនេះ។

## ២. ក្របខ័ណ្ឌគុណវុឌ្ឍិជាតកម្ពុជា ក.គ.ជ.ក (CQF)

ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (ក.គ.ជ.ក) ជាធាតុសំខាន់ចាំបាច់មួយនៅក្នុងប្រព័ន្ធធានាគុណភាព និងទទួលស្គាល់គុណភាពអប់រំដែលធានាឲ្យមានគុណភាពនៃការអប់រំជាចម្បង និងការបណ្តុះបណ្តាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.គ.ជ.ក ជាឧបករណ៍ថ្នាក់ជាតិសម្រាប់ធ្វើការអភិវឌ្ឍ និងធ្វើចំណាត់ថ្នាក់នៃគុណវុឌ្ឍិស្របតាមលក្ខណៈវិនិច្ឆ័យនៃកម្រិតសិក្សា ដែលបានសម្រេចហើយក៏ជាគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការធានាបាននូវគុណភាពអប់រំ និងបណ្តុះបណ្តាល ដែលធ្វើឲ្យលទ្ធផលសិក្សាមានលក្ខណៈស្តង់ដាច្បាស់លាស់ ព្រមទាំងមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងសហគមន៍ជាតិ និងអន្តរជាតិ។

ក.គ.ជ.ក បង្កើតឲ្យមានសមមូលភាពច្បាស់លាស់នៃស្តង់ដាគុណវុឌ្ឍិជាតិជាមួយនឹងស្តង់ដាគុណវុឌ្ឍិក្នុងតំបន់។ ក.គ.ជ.ក នឹងផ្តល់នូវចំណុចប្រៀបធៀបជាក់លាក់នៅក្នុងស្តង់ដានៃការអប់រំ និងការបណ្តុះបណ្តាលសម្រាប់គ្រឹះស្ថានសិក្សាក្នុងការធ្វើផែនការ និងដំណើរការស្វ័យត្រួតពិនិត្យសម្រាប់មន្ត្រីត្រួតពិនិត្យពីខាងក្រៅដែលពាក់ព័ន្ធក្នុងដំណើរការទទួលស្គាល់គុណភាពអប់រំលើកម្មវិធីបណ្តុះបណ្តាល និងលើគ្រឹះស្ថានសិក្សាទាំងមូល និងជួយដល់និយោជកក្នុងការស្វែងយល់ពីជំនាញ និងសមត្ថភាពរបស់សិស្សដែលបានបញ្ចប់ការសិក្សាមុននឹងជ្រើសរើសយកមកបម្រើការងារ។

ក.គ.ជ.ក ផ្តល់នូវការយល់ដឹងលើក្របខ័ណ្ឌរួមមួយដែលជាស្តង់ដាជាតិព្រមទាំងមានភាពអាចបត់បែនសម្រាប់ក្របខ័ណ្ឌគុណវុឌ្ឍិនៅក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល។ ក្របខ័ណ្ឌគុណវុឌ្ឍិនេះ ផ្តល់នូវលក្ខណៈរួម និងភាពផ្សេងពីគ្នាសំខាន់ៗមួយចំនួននៃវិស័យទាំងពីរគឺការអប់រំឧត្តមសិក្សា និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលចាំបាច់ត្រូវយល់ដឹងជាមុន។ ភាពខុសគ្នា និងទំនាក់ទំនងមួយចំនួនរវាងវិស័យទាំងពីរមានៈ

**តារាងទី១ រចនាសម្ព័ន្ធក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ក.គ.ជ.ក (CQF)**

| កម្រិត | ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ | ការអប់រំជាន់ខ្ពស់ |
|---|---|---|
| ៨ | បណ្ឌិតបច្ចេកវិទ្យា ឯកទេស | បណ្ឌិត |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា ឯកទេស | សញ្ញាបត្រជាន់ខ្ពស់ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា ឯកទេស សញ្ញាបត្រវិស្វករ | បរិញ្ញាបត្រ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្ររង ឯកទេស | បរិញ្ញាបត្ររង |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | |
| ២ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | |

ធាតុគោលរបស់គុណវុឌ្ឍិដែលកំណត់ក្នុង ក.គ.ជ.ក មាន ៤ គឺៈ កម្រិត ក្រេឌីត លទ្ធផលសិក្សា និង ច្រកសិក្សា។

- **កម្រិតៈ** កម្រិតជាលេខលំដាប់ដែលភ្ជាប់ទៅនឹងឈ្មោះគុណវុឌ្ឍិ ដើម្បីរៀបរាប់ពីតម្រូវការនៃបញ្ញា ដែលកើនឡើង និងភាពស្មុគស្មាញនៃលទ្ធផលសិក្សានៅក្នុងគុណវុឌ្ឍិនីមួយៗ។
- **ក្រេឌីតៈ** ឯកត្តា ឬតម្លៃដែលជាខ្នាតសម្រាប់វាស់វែង និងការពិពណ៌នាពីទំហំការងារ ឬបរិមាណនៃការសិក្សាដែលរំពឹងទុកសម្រាប់កម្រិតនីមួយៗ ឬសម្រាប់មុខវិជ្ជាសិក្សា ឯកសារសិក្សា ឬសមាសសភាគដទៃទៀតនៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាគោលការណ៍ ការកំណត់ចំនួនក្រេឌីតក្នុងក្របខ័ណ្ឌគុណវុឌ្ឍិនេះ គឺ១៥ម៉ោងស្មើនឹង១ក្រេឌីត សម្រាប់ការបង្រៀនក្នុងធម្មតា ៣០ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការសិក្សាប្រតិបត្តិ និងចំនួន៤៥ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការអនុវត្តជាក់ស្តែង។ ចំពោះនិស្សិតសិក្សាពេញម៉ោងនៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រក្នុងរយៈពេល ១ឆមាសត្រូវសិក្សាយ៉ាងតិចចំនួន១៥ក្រេឌីត និងយ៉ាងតិចចំនួន៣០ក្រេឌីតក្នុងរយៈពេល១ឆ្នាំសិក្សា។
- **លទ្ធផលសិក្សាៈ** ជាសេចក្តីថ្លែងនូវអ្វីដែលអ្នកសិក្សាចេះ យល់ និងអាចធ្វើបានក្រោយបញ្ចប់ការសិក្សា តាមរយៈលក្ខណៈវិនិច្ឆ័យស្នាដៃការងារផ្អែកលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងសមត្ថភាព។

- **ច្រកសិក្សា៖** ច្រកអាចបត់បែនបានដែលបង្កភាពងាយស្រួលដល់អ្នកសិក្សាក្នុងការផ្លាស់ប្តូររវាងវិស័យអប់រំឧត្តមសិក្សា និងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងការបន្តការសិក្សាកម្រិតគុណវុឌ្ឍិកម្រិតខ្ពស់បន្ថែមទៀតតាមរយៈការទទួលស្គាល់ការសិក្សា ដែលមានពីមុនរួចមានការផ្ទេរក្រេឌីត និងការទទួលស្គាល់លើសមត្ថភាពបច្ចុប្បន្ន។

## ៣. ការពិពណ៌នាអំពីវិញ្ញាបនបត្រវិជ្ជាជីវៈ

នៅកម្ពុជា ពាក្យ "វិញ្ញាបនបត្រវិជ្ជាជីវៈ" សំដៅទៅលើកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលត្រូវបានគេទទួលស្គាល់នៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) គឺគុណវុឌ្ឍិកម្រិត១។ លទ្ធផលការសិក្សារបស់វិញ្ញាបនបត្រវិជ្ជាជីវៈ និងលក្ខណៈវិនិច្ឆ័យនៃការអនុវត្តត្រូវបានធ្វើឲ្យស្របគ្នានឹងការពណ៌នាកម្រិតដែលបានផ្តល់ដោយក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា (CQF) សម្រាប់កម្រិត១។

គោលដៅរួមនៃវិញ្ញាបនបត្រវិជ្ជាជីវៈគឺផ្តល់ឲ្យអ្នកសិក្សានូវចំណេះដឹង និងជំនាញការងារជាមូលដ្ឋានដែលជំរុញឲ្យពួកគេអាចចូលធ្វើការងារបាន។ កម្មវិធីវិញ្ញាបនបត្រវិជ្ជាជីវៈមានទាំងគោលគំនិតទ្រឹស្តី និងការអនុវត្ត ដែលអ្នកសិក្សាមានឱកាសក្នុងការអនុវត្តជំនាញ និងប្រើប្រាស់ចំណេះដឹងនៅក្នុងស្ថានភាព ដែលទាក់ទងទៅនឹងការងារ។ នៅពេលដែលអ្នកសិក្សាមានចំណេះដឹង និងជំនាញដែលត្រូវមាន (បានកំណត់នៅក្នុងលទ្ធផលសិក្សានៃម៉ូឌុលនីមួយៗ) ពួកគេត្រូវបានវាយតម្លៃដោយអ្នកវាយតម្លៃ ដែលមានសមត្ថភាពដោយការបង្ហាញពីជំនាញ និងចំណេះដឹងរបស់ពួកគេ។ ប្រសិនបើអ្នកសិក្សាអាចបង្ហាញពីជំនាញ និងចំណេះដឹងរបស់ពួកគេ ដែលតម្រូវតាមស្តង់ដាដែលត្រូវបានចែងនៅក្នុងលទ្ធផលសិក្សា និងលក្ខណៈវិនិច្ឆ័យនៃការអនុវត្តនៅក្នុងកម្មវិធីសិក្សាមានន័យថាពួកគេមានសមត្ថភាព។ ម៉ូឌុលត្រូវបានទាមទារឲ្យអនុវត្តទាំងអស់ដើម្បីបញ្ចប់ការសិក្សា ហើយអ្នកសិក្សានឹងទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈក្រោយពេលវាយតម្លៃការសិក្សារួច។

គុណវុឌ្ឍិនេះផ្តល់ឱកាសឲ្យសិស្សអភិវឌ្ឍន៍ជំនាញ និងទទួលបានចំណេះដឹងគ្រប់គ្រាន់ក្នុងការអនុវត្តនីតិវិធី ដែលកំណត់ក្នុងកិច្ចការមុខរបរ សមត្ថភាពក្នុងការអនុវត្តកិច្ចការស្របតាមនីតិវិធី ឬការណែនាំផ្ទាល់ សមត្ថភាពបំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវសមត្ថភាពយល់ដឹងដែលអាចឆ្លើយតបតាមការណែនាំ និងនីតិវិធីមូលដ្ឋាន សមត្ថភាពក្នុងការប្រមូលព័ត៌មានតាមរយៈផ្ទាល់មាត់ និងរបាយការណ៍ជាសំណេរ និងសមត្ថភាពក្នុងការអនុវត្តនីតិវិធីងាយៗ ការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាមូលដ្ឋានសម្រាប់ការងារដែលទាក់ទងទៅនឹងការសិក្សា។

## ៣.១. សមត្ថភាពទូទៅ

គុណវុឌ្ឍិក្នុងកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ គឺអាចផ្តល់នូវចំណេះដឹងមុខងារមូលដ្ឋាន និងជំនាញដើម្បីធ្វើការងារ និងរៀនបន្ត។ វិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបានរៀបចំឡើងដោយយកសមត្ថភាពជាចម្បងក្នុងការបង្ហាញនៅលទ្ធផលសិក្សា។ លទ្ធផលសិក្សារបស់វិញ្ញាបនបត្រវិជ្ជាជីវៈមានលក្ខណៈសំខាន់ៗដូចខាងក្រោមៈ

- លទ្ធផលសិក្សានៃវិញ្ញាបនបត្រវិជ្ជាជីវៈមានកម្រិតចំណេះដឹង និងជំនាញទាបជាងគេបំផុតក្នុងចំណោមកម្រិតសិក្សាទាំងប្រាំបីរបស់ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។
- លទ្ធផលសិក្សានៃវិញ្ញាបនបត្រវិជ្ជាជីវៈអាចវាយតម្លៃបានតាមរយៈការវាយតម្លៃសមត្ថភាពរបស់កម្មវិធីបណ្តុះបណ្តាលនៃវិញ្ញាបនបត្រវិជ្ជាជីវៈ។
- លទ្ធផលសិក្សានៃវិញ្ញាបនបត្រវិជ្ជាជីវៈ មានលក្ខណៈដែលបង្ហាញក្នុងផ្នែកផ្សេងៗចំនួន៥គឺៈ

  ចំណេះដឹង ជំនាញក្នុងការគិត ជំនាញចិត្តចលនា ជំនាញអន្តរបុគ្គល និងការទទួលខុសត្រូវ និងជំនាញលេខនព្វន្តព័ត៌មានវិទ្យា និងទំនាក់ទំនង។

## ៣.២. ការបែងចែកលទ្ធផលសិក្សាតាមផ្នែកទាំង៥

**តារាងទី ២ ស្តីពីការបែងចែកលទ្ធផលសិក្សាតាមផ្នែកទាំង៥**

| ផ្នែក | លទ្ធផលសិក្សា |
|---|---|
| ចំណេះដឹង | មានចំណេះដឹងដែលទាក់ទងនឹងស្ថានភាពការងារអាជីពដូចជាការអនុវត្តនីតិវិធីបទបញ្ញត្តិ និងគោលគំនិតកម្រិតមូលដ្ឋាន។ |
| ជំនាញក្នុងការគិត | ប្រើចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាល និងបទពិសោធន៍ការងារតាមលំដាប់លំដោយ។ ចំណេះដឹងទាំងនេះទាក់ទងនឹងសេរីភាពក្នុងការសម្រេចចិត្តរបស់សិស្ស ប៉ុន្តែត្រូវមានសមត្ថភាពក្នុងការអនុវត្តការណែនាំផ្ទាល់របស់អ្នកគ្រប់គ្រង។ |
| ជំនាញចិត្តចលនា | មានជំនាញមូលដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍ស្តង់ដាក្នុងកិច្ចការអាជីព ហើយអាចប្រើ ជំនាញទាំងនេះក្នុងការអនុវត្តនីតិវិធីតាមស្តង់ដា។ |

| | |
|---|---|
| ជំនាញអន្តរបុគ្គល និងការទទួលខុសត្រូវ | បំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវស្របតាមការណែនាំ ឬស្របតាមស្តង់ដា នីតិវិធីក្នុងស្ថានភាពការងារដែលបានកំណត់។<br>មានការទទួលខុសត្រូវចំពោះបរិមាណ និងគុណភាពនៃលទ្ធផលរបស់ខ្លួនប៉ុន្តែមិនមែនជាការទទួលខុសត្រូវលើលទ្ធផលរបស់អ្នកដទៃ។ |
| ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង | អាចយល់ និងឆ្លើយតបទៅនឹងការណែនាំដែលទាក់ទងនឹងកិច្ចការអាជីព អាចធ្វើការទាក់ទងតាមរយៈផ្ទាល់មាត់ និងសំណេរធម្មតាក្នុងកម្រិតមូលដ្ឋានដូចជា៖ ការសរសេររបាយការណ៍លើការងារ និងកិច្ចការដែលខ្លួនបានបំពេញដែលជាទម្រង់របាយការណ៍ធម្មតា។ |

## ៣.៣. លក្ខខណ្ឌចូលរៀន

មិនមានលក្ខខណ្ឌសំខាន់ដែលតម្រូវសម្រាប់ចូលរៀនវគ្គវិញ្ញាបនបត្រវិជ្ជាជីវៈនោះទេ។ ទោះជាយ៉ាងណាអ្នកសិក្សាគួរមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ព្រមទាំងអាចអាន និងសរសេរអក្សរខ្មែរបាន។

## ៣.៤. រយៈពេលបណ្តុះបណ្តាល

រយៈពេលសិក្សាវិញ្ញាបនបត្រវិជ្ជាជីវៈគឺចាប់ ៤ ទៅ ៦ខែដោយមានក្រេឌីតសរុបចំនួន ៣០ក្រេឌីត។ ការគណនាចំនួនក្រេឌីតគឺធ្វើទៅតាមគោលការណ៍ដែលមានចែងនៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។

## ៣.៥. ប្រភេទនៃការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលសម្រាប់វិញ្ញាបនបត្រវិជ្ជាជីវៈ គឺអាចមានភាពបត់បែនតាមកាលៈទេសៈ។ ប្រភេទនៃការបណ្តុះបណ្តាលដែលអាចប្រើប្រាស់បានមានដូចជា៖

- ការអប់រំបណ្តុះបណ្តាល និងការវាយតម្លៃតាមរយៈសហគ្រាស
- ការអប់រំបណ្តុះបណ្តាល និងការវាយតម្លៃតាមរយៈគ្រឹះស្ថាន
- ការអប់រំបណ្តុះបណ្តាល និងការវាយតម្លៃតាមរយៈសហគមន៍
- ការរួមបញ្ចូលគ្នានូវរបៀបទាំងឡាយខាងលើ លើសពីនេះទៅទៀតអ្នកសិក្សាក៏អាចអនុវត្តនូវស្វ័យសិក្សា និងការសន្ទំបទពិសោធន៍ដើម្បីធ្វើតេស្តយកវិញ្ញាបនបត្រវិជ្ជាជីវៈបានផងដែរ។

## ៣.៦. ច្រកសិក្សាឬធ្វើតេស្តដើម្បីទទួលបានគុណវុឌ្ឍិ

ដើម្បីទទួលបាននូវគុណវុឌ្ឍិកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈអ្នកសិក្សាអាចប្រើប្រាស់នូវមធ្យោបាយ៤បែប ដូចខាងក្រោម៖

១. ឆ្លងកាត់វគ្គបណ្តុះបណ្តាលចាប់ពី៤ទៅ៦ខែដែលមានការទទួលស្គាល់ និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចបាននូវរាល់សមត្ថភាព ដែលកំណត់ក្នុងកញ្ចប់ឯកសារសិក្សាផ្អែកលើសមត្ថភាព។

២. មានវិញ្ញាបនបត្រវិជ្ជាជីវៈតាមរយៈការបណ្តុះបណ្តាលដែលមិនមានការទទួលស្គាល់ ត្រូវដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលដែលមានការទទួលស្គាល់ និងចុះបញ្ជិកាត្រឹមត្រូវហើយប្រឡងសម្រេចបាននូវរាល់សមត្ថភាព ដែលកំណត់ក្នុងកញ្ចប់ឯកសារធ្វើតេស្តសមត្ថភាពដែលបានអនុម័ត។

៣. មានលិខិតបញ្ជាក់ពីប្រធានក្រុមហ៊ុន ឬអ្នកគ្រប់គ្រងថាបានបំពេញការងាររយៈពេលយ៉ាងតិច១ឆ្នាំ ហើយត្រូវដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពជាប់នៅមជ្ឈមណ្ឌលដែលមានការទទួលស្គាល់ និងចុះបញ្ជិកាត្រឹមត្រូវ។

៤. មានចំណេះដឹងក្នុងការអាន ការសរសេរ និងលេខនព្វន្តស្របទៅនឹងស្តង់ដាកម្រិតមូលដ្ឋានហើយសន្សំសម្រេចរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារផ្អែកលើសមត្ថភាពកម្រិត១ តាមរយៈការបណ្តុះបណ្តាល ឬការធ្វើការងារ។

## ៤. ការធានាគុណភាព

ដើម្បីធានានិរន្តភាពនៃគុណភាពរបស់វិញ្ញាបនបត្រវិជ្ជាជីវៈគ្រឹះស្ថានដែលទទួលបន្ទុកប្រតិបត្តិផ្ទាល់ដូចជាគ្រឹះស្ថានបណ្តុះបណ្តាល និងមជ្ឈមណ្ឌលធ្វើតេស្តដែលបានចុះបញ្ជិការួចត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមសេចក្តីណែនាំនៃវិញ្ញាបនបត្រវិជ្ជាជីវៈក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងបទដ្ឋានគតិយុត្តិនានាដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លើសពីនេះទៅទៀត កម្មវិធីបណ្តុះបណ្តាលរបស់វិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវមានការអភិវឌ្ឍជាប្រចាំទៅតាមការវិវត្តនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព្រមទាំងបរិបទជាតិ បរិបទតំបន់ និងបរិបទអន្តរជាតិ។

## ៥. ការត្រួតពិនិត្យវាយតម្លៃ និងសវនកម្ម

គ្រឹះស្ថានបណ្តុះបណ្តាល និងមជ្ឈមណ្ឌលធ្វើតេស្តដែលបានចុះបញ្ជិការួច ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងវាយតម្លៃ និងសវនកម្មរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៦. សទ្ទានុក្រម

| ពាក្យ | និយមន័យក្នុងគុណវុឌ្ឍិ |
|---|---|
| ទំនួលខុសត្រូវលើការអនុវត្តចំណេះដឹង និងជំនាញ (Accountability in the application of knowledge and/or skills) | ទំនួលខុសត្រូវលើការអនុវត្តចំណេះដឹង និងជំនាញសំដៅទៅលើកម្រិតរបស់បុគ្គលម្នាក់តម្រូវឲ្យទទួលខុសត្រូវសម្រាប់អាកប្បកិរិយារបស់ខ្លួន នៅក្នុងស្ថានភាពការងារ ឬសិក្សាឲ្យសមស្របទៅនឹងកម្រិតគុណវុឌ្ឍិ។ |
| ការទទួលស្គាល់គុណភាពអប់រំ (Accreditation) | ជាដំណើរការតាមរយៈសមាគម ឬភ្នាក់ងារទទួលខុសត្រូវស្របច្បាប់ដើម្បីផ្តល់ការទទួលស្គាល់ជាសាធារណៈទៅលើសាលា មជ្ឈមណ្ឌល វិទ្យាស្ថាន មហាវិទ្យាល័យ ឬកម្មវិធីសិក្សាដែលបានបំពេញនូវស្តង់ដាអប់រំអប្បបរមា។ |
| វគ្គសិក្សាខ្លីដែលបានទទួលស្គាល់ (Accredited short course) | គឺជាកម្មវិធីសិក្សាដែលមានធាតុមួយ ឬក៏ច្រើន (ឧទាហរណ៍ ក្រុមសមត្ថភាព ម៉ូឌុល ឬមេរៀន)ដែលត្រូវបានទទួលស្គាល់ដោយអាជ្ញាធរទទួលស្គាល់គុណភាពអប់រំ។ |
| កម្មវត្ថុដែលបានទទួលស្គាល់ (Accredited unit) | គឺជាធាតុមួយនៃគុណវុឌ្ឍិឬក៏ជាក្រុមដាច់ដោយឡែកមួយដែលត្រូវបានទទួលស្គាល់ដោយដំណើរដូចគ្នានឹងគុណវុឌ្ឍិ(CQF)ទាំងមូល។ នៅអូស្ត្រាលីកម្មវត្ថុដែលបានទទួលស្គាល់អាចត្រូវបានហៅថា "ម៉ូឌុល" ឬ"មេរៀន" ក្រុមសមត្ថភាព ឬក៏កម្មវត្ថុ។ |

| | |
|---|---|
| ការអនុវត្តចំណេះដឹង និងជំនាញ<br>(Application of knowledge and/or skills) | សំដៅទៅលើអ្នកដែលបញ្ចប់ការសិក្សាអនុវត្តចំណេះដឹង និងជំនាញក្នុងបរិបទស្វ័យភាព និងទំនួលខុសត្រូវ។ |
| ការរៀបចំបញ្ចូលគ្នា<br>(Articulation arrangements) | ជំរុញឲ្យសិស្សមានភាពរីកចម្រើនពីការបញ្ចប់គុណវុឌ្ឍិទៅកាន់ការទទួលឲ្យចូលរៀន ឬទទួលបានក្រេឌីតក្នុងច្រកគុណវុឌ្ឍិដែលបានកំណត់។ |
| ការវាយតម្លៃ<br>(Assessment) | ជាដំណើរការដែលប្រមូលភស្តុតាងដើម្បីបញ្ជាក់ថា តើអ្នកសិក្សាទទួលបានតាមស្តង់ដាដែលតម្រូវដែរឬទេ? ការវាយតម្លៃក៏ត្រូវបានប្រើជាផ្នែកមួយនៃដំណើរការសិក្សាដើម្បីជួយដល់អ្នកសិក្សាក្នុងការធ្វើឲ្យមានការរីកចម្រើន។ |
| ស្វ័យភាពក្នុងការអនុវត្តចំណេះដឹង និងជំនាញ<br>(Autonomy in the application of knowledge and/or skills) | គឺជាសមត្ថភាពអនុវត្តចំណេះដឹង ឬជំនាញនៅកម្រិតឯករាជ្យស្របតាមកម្រិតគុណវុឌ្ឍិជាតិ។ |
| ចំណេះដឹង ឬ ជំនាញមូលដ្ឋាន<br>(Basic knowledge and/or skills) | រួមមានចំណេះដឹង និងជំនាញដែលបង្កើតឲ្យមានចំនុចចាប់ផ្តើមឬជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍការសិក្សា និងការងារ។ |
| ចំណេះដឹង និងជំនាញទូលំទូលាយ<br>(Broad knowledge and/or skills) | ការពិពណ៌នាអំពីការសិក្សា ឬការងារទូទៅ និងផ្នែកជំនាញធំទូលាយមួយ។ |

| | |
|---|---|
| ក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា (Cambodian Qualifications Framework) | គឺជាឧបករណ៍សម្រាប់ការអភិវឌ្ឍ និងបែងចែកគុណវុឌ្ឍិដែលផ្អែកទៅលើកម្រងលក្ខណៈវិនិច្ឆ័យដែលបានយល់ព្រមពីថ្នាក់ជាតិសម្រាប់កម្រិតជាក់លាក់ណាមួយនៃការសម្រេចបានផ្អែកលើការសិក្សា។ វាគឺជាគោលនយោបាយនិងយុទ្ធសាស្ត្រក្នុងការអប់រំបណ្តុះបណ្តាលធានាគុណភាព ដែលបញ្ជាក់ពីស្តង់ដានៃលទ្ធផលសិក្សាតាមកម្រិតការសិក្សា និងគុណភាពគុណវុឌ្ឍិហើយត្រូវបានទទួលស្គាល់ក្នុងការសិក្សាអន្តរជាតិ និងសហគមន៍អាជីព។ |
| វិញ្ញាបនបត្រ (Certification) | ដំណើរការនៃចំណេះដឹង ដែលមានសុពលភាពជាផ្លូវការ ត្រូវចេះពីរបៀបធ្វើ ឬជំនាញ និងសមត្ថភាពដែលបានទទួលដោយបុគ្គលម្នាក់ធ្វើតាមនីតិវិធីវាយតម្លៃស្តង់ដានាំទៅរកការទទួលបានគុណវុឌ្ឍិតាមរយៈស្ថាប័នដែលផ្តល់គុណវុឌ្ឍិ។ |
| ឯកសារវិញ្ញាបនបត្រ (Certification documentation) | គឺជាកម្រងនៃឯកសារផ្លូវការដែលបញ្ជាក់ថាគុណវុឌ្ឍិត្រូវបានបញ្ចប់ និងត្រូវបានផ្តល់ដល់បុគ្គលនោះ។ |
| ជំនាញក្នុងការគិត (Cognitive skills) | រួមមានជំនាញផ្លូវចិត្ត ដែលត្រូវបានប្រើក្នុងដំណើរការទទួលបាន និងអនុវត្តចំណេះដឹង រួមមានការវែកញែកហេតុផលការយល់ឃើញ និងវិចារណញាណ។ |
| ជំនាញទំនាក់ទំនង (Communication skills) | ជំនាញដែលជំរុញឲ្យផ្ញើព័ត៌មានដើម្បីទទួលបាន និងយល់ពីព័ត៌មាន ហើយនិងជំនាញសរសេរ ឬផ្ទាល់មាត់សមស្របទៅនឹងកម្រិតគុណវុឌ្ឍិជាតិ។ |
| សមត្ថភាព (Competence) | សមត្ថភាពក្នុងការប្រើចំណេះដឹង ជំនាញសមត្ថភាពបុគ្គល សង្គមឬវិធីសាស្ត្រក្នុងបរិបទការងារ ឬសិក្សា និងការអភិវឌ្ឍន៍បុគ្គល និងអាជីព។ |
| សមត្ថភាព (Competency) | សមត្ថភាពគឺជាការមានចំណេះ ហើយអនុវត្តចំណេះដឹង ជំនាញ និងអាកប្បកិរិយាក្នុងការធ្វើសកម្មភាពការងារឲ្យដល់ស្តង់ដាដែលរំពឹងទុកនៅកន្លែងការងារ។ |
| កម្មវិធីសិក្សាផ្អែកលើសមត្ថភាព (Competency-based curriculum) | ការបញ្ជាក់លម្អិតសម្រាប់វគ្គសិក្សាដែលផ្អែកទៅលើចំណេះដឹង ជំនាញ និងសមត្ថភាព ធ្វើការដែលមានប្រសិទ្ធភាពដែលត្រូវបានបញ្ជាក់ច្បាស់លាស់ ហើយភ្ជាប់យ៉ាងជិតស្និតជាមួយស្តង់ដាសមត្ថភាព។ |

| | |
|---|---|
| អាជ្ញាធរ CQF<br>(CQF Authority) | អង្គភាពអាជ្ញាធរ ដែលត្រូវបានបង្កើតឡើងក្រោមក្រុមប្រឹក្សាកំពូលផ្នែកអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មុខងារចម្បងរបស់ (CQF) គឺគ្រប់គ្រងការអនុវត្ត និងវឌ្ឍនកម្មនៃគុណវុឌ្ឍិ (CQF)។ |
| ការប្រមូលក្រេឌីត<br>(Credit accumulation) | ដំណើរការទទួលបានក្រេឌីតពីគុណវុឌ្ឍិនៅតាមគ្រឹះស្ថាន(ឧទាហរណ៍ គុណវុឌ្ឍិទាំងអស់ត្រូវផ្តល់ដោយស្ថាប័នផ្តល់គុណវុឌ្ឍិតែមួយគត់)។ |
| កម្មវិធីសិក្សា<br>(Curriculum) | ជាសំណុំនៃការងារទៅតាមពេលនៃការអភិវឌ្ឍកម្មវិធីសិក្សារួមមាន ការកំណត់គោលដៅខ្លឹមសារវិធីសាស្រ្ត (រួមទាំងការវាយតម្លៃ) និងសម្ភារៈនៃការបណ្តុះបណ្តាល។ |
| ជម្រៅចំនេះដឹង/ជំនាញ<br>(Depth of knowledge/skills) | បង្ហាញពីកម្រិតនៃភាពពិបាក ឬភាពស្មុគស្មាញ។ |
| លទ្ធផលសិក្សាទូទៅ<br>(Generic learning outcomes) | សំដៅទៅលើជំនាញដែលអាចផ្ទេរបាន ដែលអ្នកបានបញ្ចប់ការសិក្សាបានសម្រេចតាមរយៈការសិក្សាដែលអាចអនុវត្តក្នុងស្ថានភាពសិក្សាអំពីការងារឬជីវិត។ ផ្នែកធំៗទាំង៤នៃគុណវុឌ្ឍិ (CQF) គឺជំនាញមូលដ្ឋានៈ<br>ជំនាញធនធានមនុស្ស ជំនាញគិត និងជំនាញបុគ្គល។ |
| អ្នកបញ្ចប់ការសិក្សា<br>(Graduate) | គឺជាអ្នកដែលបានទទួលគុណវុឌ្ឍិ គឺអង្គភាពដែលទទួលបានការអនុញ្ញាត។ |
| អ្នកផ្តល់ការអប់រំជាន់ខ្ពស់<br>(Higher education provider) | ស្ថាប័នសាជីវកម្ម អង្គការ ឬក្រុមមនុស្សដែលធ្វើកម្មវិធីអប់រំបណ្តុះបណ្តាលជាន់ខ្ពស់ រួមមានកម្មវិធីបណ្តុះបណ្តាលជំនាញដែលនាំឲ្យទទួលបានគុណវុឌ្ឍិជាន់ខ្ពស់ ឬគុណវុឌ្ឍិអប់រំជាន់ខ្ពស់ និងរួមទាំងអ្នកផ្តល់ការអប់រំជាន់ខ្ពស់ ទាំងសាធារណៈ និងឯកជន ការប្រលង ឬវិញ្ញាបនកម្ម ឬអ្នកតំណាងរបស់ពួកគេ។ |
| ការសិក្សាក្រៅប្រព័ន្ធ<br>(Informal learning) | ការសិក្សាដែលទទួលបានតាមរយៈការងារសង្គម គ្រួសារ ចំណង់ចំណូលចិត្ត សកម្មភាពពេលទំនេរ និងបទពិសោធន៍ មិនដូចជាការសិក្សាក្នុងប្រព័ន្ធ ឬមិនផ្លូវការ ការសិក្សានេះមិនត្រូវបានរៀបចំរចនាសម្ព័ន្ធ ដូចគោលបំណងតាមពេលវេលា និងការគាំទ្រការសិក្សាណាមួយឡើយ។ |

| | |
|---|---|
| ចំណេះដឹង (Knowledge) | សំដៅទៅលើអ្វីដែលអ្នកបញ្ចប់ការសិក្សាចេះ និងយល់ហើយវាអាចពិពណ៌នាថាមានលក្ខណៈស៊ីជម្រៅដូចជាទំហំនៃប្រភេទចំណេះដឹង និងភាពស្មុគស្មាញ។ |
| ការសិក្សា (Learning) | គឺជាដំណើរការដែលបុគ្គលម្នាក់ជ្រួតជ្រាបពីព័ត៌មានគំនិត សកម្មភាព និងតម្លៃ ហើយទទួលបានចំណេះដឹង ជំនាញ ឬការអនុវត្តចំណេះដឹង និងជំនាញ។ |
| លទ្ធផលការសិក្សា (Learning outcomes) | ជាសេចក្តីថ្លែងនូវអ្វីដែលអ្នកសិក្សាចេះយល់ និងអាចធ្វើបានក្រោយបញ្ចប់ការសិក្សា តាមរយៈលក្ខណៈវិនិច្ឆ័យស្នាដៃការងារផ្អែកលើចំណេះដឹងជំនាញ អាកប្បកិរិយា និងសមត្ថភាព។ |
| លទ្ធផលការសិក្សា (Learning outcomes) | ការបង្ហាញពីបណ្តុំនៃចំណេះដឹង ជំនាញ និងការអនុវត្តនៃចំណេះដឹង និងជំនាញដែលបុគ្គលទទួលបាននឹងអាចបង្ហាញវាជាលទ្ធផលនៃការសិក្សា។ |
| កម្មវិធីសិក្សា (Learning programme) | ជាកម្មវិធីនៃការសិក្សា ឬការបណ្តុះបណ្តាលកំណត់ដោយកម្មវិធីសិក្សា ដែលមានម៉ូឌុល មេរៀន កម្មវត្ថុ ឬមុខវិជ្ជា ឬការផ្តុំនៃធាតុទាំងនោះ។ |
| ការពណ៌នាកម្រិតគុណវុឌ្ឍិ (Level descriptor) | និយមន័យលក្ខណៈនៃគុណវុឌ្ឍិ ដែលអាចនាំឲ្យឈានទៅកាន់កម្រិតជាក់លាក់ណាមួយ។ |
| កម្រិត (levels) | កម្រិត CQF គឺជាការបង្ហាញនៃភាពស្មុគស្មាញ និងជម្រៅនៃការសម្រេចបាន ឬស្វ័យភាពដែលតម្រូវឲ្យបង្ហាញពីការសម្រេចបានទាំងនោះ។<br>CQFកម្រិត១ មានភាពស្មុគស្មាញតិចបំផុត និងCQFកម្រិត៨ មានភាពស្មុគស្មាញខ្ពស់បំផុត។ |
| លក្ខណៈវិនិច្ឆ័យកម្រិត (Levels criteria) | លក្ខណៈវិនិច្ឆ័យកម្រិត CQF ពិពណ៌នាពីភាពស្មុគស្មាញ និងជម្រៅនៃការសម្រេចបាន និងស្វ័យភាពដែលតម្រូវអោយបង្ហាញពីការសម្រេចបានកម្រិតគុណវឌ្ឍិ CQF ១ ដល់ ៨ ។ |
| កម្រិតសង្ខេប (Levels summaries) | CQF កម្រិតសង្ខេបគឺជាសេចក្តីថ្លែងនៃការសម្រេចបានរបស់អ្នកបញ្ចប់ការសិក្សាដែលទទួលបានគុណវុឌ្ឍិនៅកម្រិតណាមួយនៅក្នុងកម្រិត CQF។ |

| | |
|---|---|
| ការសិក្សាពេញមួយជីវិត<br>(Lifelong learning) | គឺជាពាក្យប្រើសម្រាប់ពិពណ៌នាអំពីសកម្មភាពសិក្សាផ្សេងៗ ដែលបានធ្វើនៅក្នុងជីវិតដើម្បីទទួលបានចំណេះដឹង ជំនាញ និងការអនុវត្តចំណេះដឹងក្នុងបរិបទផ្ទាល់ខ្លួន សង្គម និងការទាក់ទងទៅនឹងមុខរបរ។ |
| ម៉ូឌុល<br>(Module) | ជាសមាសភាគរបស់គុណវុឌ្ឍិដែលមានវិសាលភាពធំត្រូវបានធ្វើវិញ្ញាបនបត្រដាច់ដោយឡែក ឬឯករាជ្យពីគ្នា។ (ជួនកាលវាមានន័យថាជាសមាសភាគនៃការបង្រៀន និងរៀននៅក្នុងកម្មវិធីអប់រំ ដែលមិនត្រូវបានធ្វើវិញ្ញាបនបត្រដាច់ដោយឡែកពីគ្នាទេ)។ |
| ក្របខ័ណ្ឌការទទួលស្គាល់គ្នាទៅវិញទៅមក<br>Mutual Recognition Framework (MRF) | គឺជាសមាសភាពដ៏ធំមួយនៃគុណវុឌ្ឍិដែលត្រូវបានទទួលស្គាល់ដោយឯករាជ្យ។ (ពេលខ្លះវាមានន័យថាសមាសភាពនៃការរៀន និងការបង្រៀននៅក្នុងកម្មវិធីមួយមិនត្រូវបានទទួលស្គាល់ដោយឯករាជ្យ) ។ |
| ការសិក្សាមិនមែនផ្លូវការ<br>(Non-formal learning) | សំដៅទៅលើការសិក្សាដែលកើតឡើងតាមរយៈកម្មវិធីសិក្សា ប៉ុន្តែមិននាំឲ្យទទួលបានគុណវុឌ្ឍិដែលទទួលស្គាល់ជាផ្លូវការឡើយ។ |
| សញ្ញាណម៉ោងសិក្សា<br>(Learning hours) | រួមមានសកម្មភាពសិក្សាក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធការងារជាក់ស្តែង និងការអនុវត្ត និងសកម្មភាពដែលទាក់ទងនឹងការវាយតម្លៃទាំងអស់។ |
| ច្រកសិក្សា<br>(Pathways) | ច្រកសិក្សាអនុញ្ញាតឲ្យសិស្សឆ្លងពីកម្រិតគុណវុឌ្ឍិដែលមានការទទួលស្គាល់ពេញលេញ ឬដោយផ្អែកលើលទ្ធផលសិក្សាដែលពួកគេមានស្រាប់។ ការផ្ទេរក្រេឌីត ការទទួលស្គាល់ការសិក្សាពីមុនមក និងការរួមបញ្ចូលគ្នា (សូមមើលក្រេឌីត ២.១ ក្នុងរចនាសម្ព័ន្ធ)។ |
| ចំណេះដឹង និងជំនាញជាក់ស្តែង<br>(Practical knowledge and skills) | ចំណេះដឹង និងជំនាញជាក់ស្តែង គឺជាចំណេះដឹង ឬជំនាញដែលពិត និងអាចប្រើប្រាស់បាន។ |

| | |
|---|---|
| កម្មវិធីសិក្សា<br>(Program of learning) | វគ្គសិក្សា កម្មវិធីសិក្សា ឬកញ្ចប់កម្មវិធីបណ្តុះបណ្តាល កម្មវគ្គសិក្សា និងការសិក្សានៅកន្លែងការងារដែលនាំឲ្យទទួលបានគុណវុឌ្ឍិ។ |
| អ្នកផ្តល់ការអប់រំ និងបណ្តុះបណ្តាល<br>(Provider of education and training) | អង្គភាពអប់រំ និងបណ្តុះបណ្តាល (វិទ្យាស្ថាន អង្គការ មជ្ឈមណ្ឌល ក្រុមហ៊ុនភាពជាដៃគូសហការ ឬទីប្រឹក្សាយោបល់) ដែលចែកចាយកម្មវិធីសិក្សាដែលតម្រង់ទៅស្តង់ដាគុណវុឌ្ឍិ (CQF) ត្រូវយល់ច្បាស់លាស់អំពីគុណវុឌ្ឍិ ការគ្រប់គ្រងការវាយតម្លៃលទ្ធផលផ្លូវការនៃការវាយតម្លៃ និងដំណើរការសុពលភាពដែលទទួលបាននូវការទទួលស្គាល់ ដោយស្ថាប័នផ្តល់គុណវុឌ្ឍិត្រូវកំណត់ថាបុគ្គលនោះសម្រេចបានលទ្ធផលសិក្សាស្របតាមគុណវុឌ្ឍិជាតិ។ |
| កម្រិតគុណវុឌ្ឍិ<br>(Qualification level) | កម្រិតនៃការផ្តល់វិញ្ញាបនបត្រដែលពិពណ៌នាពីលទ្ធផលទូទៅ ឬការពិពណ៌នាកម្រិតគុណវុឌ្ឍិដែលបង្ហាញពីលក្ខណៈនៃគុណវុឌ្ឍិធម្មតា។ កម្រិតត្រូវបានដាក់លេខ និងផ្សាភ្ជាប់ទៅនឹងឈ្មោះគុណវុឌ្ឍិដើម្បីពិពណ៌នាពីការកើនឡើងនៃតម្រូវការផ្នែកបញ្ញា និងភាពស្មុគស្មាញរបស់ការសិក្សាដែលត្រូវបានគេរំពឹងទុកថាជាការរីកចម្រើនរបស់សិស្សដើម្បីទទួលបានសញ្ញាបត្រអប់រំបច្ចេកទេសជាន់ខ្ពស់។ |
| គុណវុឌ្ឍិ<br>(Qualification) | ជាបណ្តុំសមត្ថភាពដែលឆ្លើយតបទៅនឹងតួនាទីការងារ និងជាផ្នែកសំខាន់នៅកន្លែងធ្វើការ។ វាក៏ជាវិញ្ញាបនបត្រដែលផ្តល់ឲ្យបន្ទាប់ពីបញ្ចប់វគ្គសិក្សា និងបានបង្ហាញសមត្ថភាពក្នុងវិស័យឧស្សាហកម្មណាមួយ។<br>វិញ្ញាបនបត្រ និងសញ្ញាបត្រដែលត្រូវទទួលបានពីអ្នកផ្តល់សេវាកម្មអប់រំជាន់ខ្ពស់ ឬក៏ការប្រគលគុណវុឌ្ឍិនឹងត្រូវបញ្ជាក់ពីលទ្ធផលសិក្សា ដែលទទួលបានពីក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជាដែលត្រូវបានកំណត់ដូចខាងក្រោមៈ<br>វិញ្ញាបនបត្រផ្លូវការដែលចេញដោយអង្គភាពពាក់ព័ន្ធផ្តល់ដោយគុណវុឌ្ឍិក្នុងការទទួលស្គាល់ថាបុគ្គលម្នាក់បានសម្រេចបាននូវលទ្ធផលនៃការសិក្សាឬមានសមត្ថភាពដែលពាក់ព័ន្ធទៅនឹងការកំណត់លក្ខណៈបុគ្គលដែលមានជំនាញវិជ្ជាជីវៈក្នុងវិស័យឧស្សាហកម្ម និងសហគមន៍។ |
| ក្របខ័ណ្ឌគុណវុឌ្ឍិ<br>(Qualification Framework) | ជាឧបករណ៍សម្រាប់ការធ្វើចំណាត់ថ្នាក់នៃគុណវុឌ្ឍិ ដែលផ្អែកទៅលើលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់សម្រាប់កម្រិតគុណវុឌ្ឍិ ដែលសម្រេចបានជាក់លាក់ដោយធ្វើឲ្យមានតម្លាភាពទៅតាមច្រកចូលសិក្សា និងមានវឌ្ឍនភាពដោយផ្អែកលើគុណភាពនៃគុណវុឌ្ឍិ។ |

| | |
|---|---|
| លំដាប់<br>(Order) | លំដាប់ គឺជាតំបន់នៃដែនកំណត់នៃការប្រែប្រួលដែលជាច្រកតូចចង្អៀត ឬទូលាយទៅតាមដែនកំណត់នៃចំណេះដឹង និងជំនាញ។ |
| ការទទួលស្គាល់អំពីការសិក្សាដែលមានពីមុន<br>(Recognition of prior learning) | គឺជាដំណើរការវាយតម្លៃដែលទាក់ទងនឹងការវាយតម្លៃអំពីការសិក្សាដែលមានពីមុន និងការពាក់ព័ន្ធ (រួមមានការសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនមែនផ្លូវការ) ដើម្បីធ្វើការកំណត់លទ្ធផលក្រេឌីតរបស់បុគ្គលដែលដាក់ពាក្យសុំក្រេឌីតសិក្សា។ |
| ក្របខ័ណ្ឌគុណវុឌ្ឍិភូមិភាគ<br>Regional qualifications framework (RQF) | ក្របខ័ណ្ឌដែលជាគោលការណ៍សំខាន់ៗ គឺជា៖ ការអនុវត្តនីតិវិធី និងវាក្យស័ព្ទ ឬជាស្តង់ដាដើម្បីធ្វើឲ្យប្រាកដថាមានការប្រៀបធៀបក្នុងកម្រិតគុណវុឌ្ឍិ ឬក្រេឌីតដែលធ្វើឲ្យមានប្រសិទ្ធភាពនៅទូទាំងប្រទេសក្នុងតំបន់។ |
| ការងារជំនាញ<br>(Skilled work) | គឺជាលទ្ធផលដែលទាមទារឲ្យមានចំណេះដឹងសំខាន់ៗ ឬជំនាញ និងការបណ្តុះបណ្តាលឯកទេសផ្សេងៗ។ |
| ជំនាញ<br>(Skills) | សំដៅទៅលើអ្វីអ្នកដែលបានបញ្ចប់ការសិក្សា និងអាចធ្វើការអនុវត្តបាន។ ជំនាញទាំងនោះអាចជាប្រភេទ ឬភាពស្មុគស្មាញ និងរួមទាំងជំនាញក្នុងការគិត ជំនាញបច្ចេកទេស ជំនាញទំនាក់ទំនង ជំនាញច្នៃប្រឌិត ជំនាញអន្តរបុគ្គល និងជំនាញទូទៅផ្សេងៗទៀត។ |
| ចំណេះដឹង និងជំនាញឯកទេស<br>(specialized knowledge and/or skills) | សំដៅទៅលើអ្វីដែលទទួលបានហើយមានការយល់ដឹងច្បាស់លាស់ និងការបញ្ជាក់ដ៏ជាក់លាក់នៃចំណេះដឹង និងជំនាញដែលតម្រូវឲ្យមានក្នុងកម្រិតCQF ណាមួយ។ |
| សេចក្តីថ្លែងការណ៍នៃការទទួលស្គាល់<br>Statement of attainment | ការទទួលស្គាល់ថាផ្នែកនីមួយៗឬក៏ច្រើនជាងមួយ ដែលត្រូវបានទទួលស្គាល់នូវអ្វីដែលសម្រេចបានទៅតាមគោលបំណងនៃការទទួលស្គាល់។ |

| | |
|---|---|
| ជំនាញបច្ចេកទេស<br>(Technical skills) | ជំនាញប្រតិបត្តិការដែលចាំបាច់សម្រាប់សកម្មភាពការងារ ឬការសិក្សាផ្សេងៗ។ |
| កញ្ចប់កម្មវិធីបណ្តុះបណ្តាល<br>(Training package) | សំដៅទៅលើឯកសារដែលដាក់ឲ្យប្រើប្រាស់ និងចេញដោយ NTB រួមមានស្តង់ដាសមត្ថភាពគុណវុឌ្ឍិជាតិ និងគោលការណ៍ណែនាំអំពីការបណ្តុះបណ្តាលសម្រាប់វិស័យមុខរបរជាក់លាក់ណាមួយដែលបានកំណត់។ បទប្បញ្ញត្តិអំពីការបណ្តុះបណ្តាលជាមូលដ្ឋានសម្រាប់ការបង្កើតគុណវុឌ្ឍិ និងវិញ្ញាបនបត្ររបស់ CQF។ វាក៏ជាការណែនាំសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើសមត្ថភាព និងជាឧបករណ៍ណែនាំសម្រាប់កម្មវិធីTVET ដែលផ្តល់ដោយគ្រឹះស្ថានTVET ទាំងអស់។ |
| អន្តរក្របខ័ណ្ឌគុណវុឌ្ឍិ<br>Transitional qualification framework (TQF) | ឧបករណ៍បកប្រែសម្រាប់ការបែងចែកគុណវុឌ្ឍិថ្នាក់តំបន់ និងពិភពលោកដោយផ្អែកទៅលើកម្រងលក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតនៃការសិក្សាជាក់លាក់ណាមួយដែលសម្រេចបានដើម្បីឲ្យការផ្ទេរក្រេឌីតមានភាពប្រសើរឡើង និងបង្កើតយន្តការទទួលស្គាល់រវាងការចូលរួមរបស់ប្រទេសក្នុងតំបន់ និងពិភពលោក។ |
| ផ្នែកសមត្ថភាព<br>Unit of competency | គឺជាសមាសភាគនៃស្តង់ដារបស់សមត្ថភាព ដែលបញ្ជាក់ពីមុខងារ ឬតួនាទីសំខាន់ៗក្នុងការងារ ឬមុខរបរផ្សេងៗ។ វាគឺជាសមាសភាគតូចបំផុតនៃសមិទ្ធផលសម្រេចបានដែលអាចនាំឲ្យមានការវាយតម្លៃ និងការដំណើរការវិញ្ញាបនកម្មពី CQF។ |
| សុពលភាព<br>(ភាពត្រឹមត្រូវ)<br>(Validation) | ដំណើរការដែលភ្នាក់ងារ ឬសមាគមគឺត្រូវបានទទួលស្គាល់ស្របច្បាប់ដែលបានកំណត់ថាតើគុណវុឌ្ឍិដែលផ្អែកទៅលើអ្នកផ្តល់សេវាកម្ម និងសេវាកម្មថ្នាក់ជាតិដែលមានគ្រប់លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការចុះបញ្ជិកាក្នុងក្របខ័ណ្ឌគុណវុឌ្ឍិ ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់នៃការសម្រេចបានរបស់បុគ្គល គឺជាលទ្ធផលសិក្សាដែលតម្រូវឲ្យមានក្នុងការសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនមែនផ្លូវការដោយមិនគិតពីពេលវេលា និងទីកន្លែង។ |